# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២២

ខិត្តប័ណ្ណព័ត៌មាន




*ខែតុលា ឆ្នាំ២០២៤*

ទិន្នន័យដែលបានផ្សព្វផ្សាយនៅក្នុងខិត្តបណ្ណព័ត៌មាននេះ គឺបានដកស្រង់ចេញពីរបាយការណ៍អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២២ ផលិតដោយវិទ្យាស្ថានជាតិស្ថិតិ (វ.ជ.ស) នៃក្រសួងផែនការ សហការជាមួយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (ក.ស.ក) ដោយមានការជួយគាំទ្របច្ចេកទេសពីអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ (FAO) ក្រោមវិសាលភាពគំនិតផ្តួចផ្តើមគម្រោង ៥០x២០៣០ ដើម្បីបញ្ចប់កង្វះខាតទិន្នន័យស្ថិតិកសិកម្ម។ គម្រោង ៥០x២០៣០ គឺជាគំនិតផ្តួចផ្តើមដែលបានអនុវត្តដែលមានម្ចាស់ជំនួយច្រើនចូលរួមគ្នា ធនាគារពិភពលោក អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ និងមូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍកសិកម្ម មានគោលបំណងតែមួយ កសាងសមត្ថភាពស្ថិតិជាតិ និងបង្កើតប្រព័ន្ធប្រមូលទិន្នន័យស្ថិតិកសិកម្មប្រកបដោយប្រសិទ្ធភាព និងស្ថេរភាពយូរអង្វែង។

## ១. ទិដ្ឋភាពទូទៅនៃវិធីសាស្ត្រអង្កេត

ក្នុងអំឡុងខែតុលា ដល់ខែវិច្ឆិកា ឆ្នាំ២០២២ ស្ថាប័នរាជរដ្ឋាភិបាលកម្ពុជាចំនួនពីរ វ.ជ.ស និង ក.ស.ក បានអនុវត្តធ្វើអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២២ បន្ទាប់ពីបានធ្វើអង្កេតចន្លោះជំរឿនកសិកម្មឆ្នាំ២០១៩ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០ និងអង្កេតកសិកម្មឆ្នាំ២០២១។ អង្កេតកសិកម្មថ្នាក់ជាតិនេះបានប្រមូលព័ត៌មានស្តីពីការដាំដុះដំណាំ ការចិញ្ចឹមបសុសត្វ និងបសុបក្សី ការធ្វើវារីវប្បកម្ម និងនេសាទ វិធីសាស្ត្រផលិតកម្ម និងបរិស្ថាន។

**រូបទី១៖ ទិដ្ឋភាពទូទៅនៃវិធីសាស្ត្រអង្កេត**




ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២២

វិធីសាស្ត្រជ្រើសរើសសំណាកគំរូ CAS2022 ត្រូវបានធ្វើឡើងដោយផ្អែកលើសំណាកគំរូរ CAS2021 តាមវិធីសាស្ត្រស្ថិតិ។ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២១ បានប្រើប្រាស់វិធីសាស្ត្រស្ថិតិជ្រើសរើសសំណាកគំរូមណ្ឌលអង្កេត (EA) តំណាងឱ្យទូទាំងប្រទេសកម្ពុជាដោយប្រើបញ្ជីមេ (Sampling Frame) ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩។ គ្រួសារទាំងអស់នៅក្នុងមណ្ឌលអង្កេតដែលបានជ្រើសរើស ត្រូវបានចុះបញ្ជីដើម្បីស្វែងរកគ្រួសារចូលរួមធ្វើសកម្មភាពកសិកម្ម។ ការប្រើប្រាស់ព័ត៌មានជាមូលដ្ឋាននេះ គ្រួសារកាន់កាប់កសិកម្ម ត្រូវបាន រៀបចំចាត់ថ្នាក់ និងជ្រើសរើសសំណាកគំរូតាមសកម្មភាពកសិកម្មនីមួយៗ ដើម្បីប្រមូលទិន្នន័យបន្ថែម។ ការកាន់កាប់អង្គភាពកសិកម្មតាមច្បាប់ ឬជាសហគ្រាសកសិកម្មខ្នាតធំដែលគ្រប់គ្រងដោយក្រុមហ៊ុន សាជីវកម្ម ស្ថាប័នរដ្ឋ ដីសម្បទានសេដ្ឋកិច្ចក៏ត្រូវបានធ្វើអង្កេតផងដែរ ដោយផ្អែកលើបញ្ជីឈ្មោះដែលបានផ្តល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការិយាល័យរដ្ឋាភិបាលដទៃទៀត ដែលត្រូវបានដឹងច្បាស់សហគ្រាសកសិកម្មខ្នាតធំស្របច្បាប់។

CAS 2022 បានប្រើប្រាស់ម៉ាស៊ីនថេប្លេត (CAPI) ក្នុងការប្រមូលទិន្នន័យដោយផ្ទាល់ជាមួយអ្នកតបសម្ភាសន៍ ដើម្បីកត់ត្រា និងគ្រប់គ្រងទិន្នន័យ។



*ប្រភពរូបថត៖ វិទ្យាស្ថានជាតិស្ថិតិឆ្នាំ២០២២*

ការធ្វើសម្ភាសន៍គ្រួសារកសិកម្មចាប់ផ្តើមពីថ្ងៃទី៣១ ខែតុលាដល់ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២២ ហើយការធ្វើសម្ភាសន៍សហគ្រាសកសិកម្មខ្នាតធំចាប់ផ្តើមពីថ្ងៃទី១៣ ដល់ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២២។ មន្ត្រីទាំងអស់ដែលបានចូលរួមអង្កេតសរុបមានចំនួន ៤២៩ នាក់ (ក្នុងនោះមន្ត្រីសម្ភាសន៍ចំនួន ៣៣៧នាក់ មន្ត្រីត្រួតពិនិត្យការសម្ភាសន៍ចំនួន ៤៦ នាក់ និងមន្ត្រីត្រួតពិនិត្យគុណភាពទិន្នន័យចំនួន ៤៦ នាក់) ទិន្នន័យគ្រួសារកាន់កាប់កសិកម្មដែលបានសម្ភាសន៍ប្រមូលទិន្នន័យពេញលេញមានចំនួន ១៥ ៧៥១ គ្រួសារ និងសហគ្រាសកសិកម្មខ្នាតធំចំនួន ៤០៧ សហគ្រាសនៅទូទាំង២៥ រាជធានីខេត្ត នៅកម្ពុជាត្រូវបានសម្ភាសន៍ផងដែរ។

ខិត្តប័ណ្ណព័ត៌មានស្ថិតិ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២២ បង្ហាញអំពីរបកគំឃើញសំខាន់ៗ សម្រាប់តែការកាន់កាប់កសិកម្មគ្រួសារតែប៉ុណ្ណោះ។

## ២. គ្រួសារកាន់កាប់កសិកម្ម

អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២២ ត្រូវបាន់ប្រមាណថានៅកម្ពុជាមានគ្រួសារកាន់កាប់កសិកម្មសរុបចំនួន ១ ៨៥៨ ៥៤០ គ្រួសារ។ ផ្អែកតាមទិន្នន័យជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ ត្រូវបានប៉ាន់ប្រមាណថានៅទូទាំងប្រទេសកម្ពុជាមានគ្រួសារសរុបចំនួន ៣ ៥៥៣ ០២១ គ្រួសារ ដូច្នេះមានការប៉ាន់ប្រមាណ ៥២ ភាគរយ នៃចំនួនសរុបត្រូវបានចូលរួមក្នុងផលិតកម្មកសិកម្ម។

គ្រួសារកាន់កាប់កសិកម្មទាំងនេះ ត្រូវបានបែងចែកមិនស្មើគ្នានៅទូទាំងប្រទេសតំបន់ភូមិសាស្ត្ររួមមាន៖ តំបន់វាលទំនាបមានគ្រួសារកាន់កាប់កសិកម្មច្រើនជាងគេមានដល់ទៅ ៤១ ភាគរយ បន្ទាប់មកគឺ តំបន់បឹងទន្លេសាបមាន ៣៨ ភាគរយ តំបន់ភ្នំ និងខ្ពង់រាបមាន ១៥ ភាគរយ និងចុងក្រោយតំបន់ឆ្នេរសមុទ្រមានតែ ៧ ភាគរយ។

**រូបទី២ ៖ គ្រួសារកសិកម្មចែកតាមតាមតំបន់**




**រូបទី៣ ៖ ចំនួន និងភាគរយនៃគ្រួសារកសិកម្មចែកតាមតាមតំបន់ (គិតជាពាន់)**




ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២២

គ្រួសារកាន់កាប់កសិកម្មនៅក្នុងប្រទេសកម្ពុជា បានរាយការណ៍ថា៖ មានរហូតដល់ ៦១ ភាគរយ ធ្វើកសិកម្មក្នុងគោលបំណងចម្បងសម្រាប់ទុកប្រើប្រាស់ក្នុងគ្រួសារ ហើយមានតែ ៣៩ ភាគរយប៉ុណ្ណោះបានធ្វើកសិកម្ម ក្នុងគោលបំណងចម្បងសម្រាប់លក់។ បំណែងចែកតាមតំបន់មាន ៨៨ ភាគរយ នៃគ្រួសារកសិកម្មនៅតំបន់ឆ្នេរសមុទ្រ បានធ្វើកសិកម្មក្នុងគោលបំណងចម្បងសម្រាប់ទុកប្រើប្រាស់ក្នុងគ្រួសារ បន្ទាប់មកមាន ៦៥ ភាគរយ នៃគ្រួសារកសិកម្ម នៅតំបន់ភ្នំ និងខ្ពង់រាប ហើយមាន ៦៣ ភាគរយ នៃគ្រួសារកសិកម្ម នៅតំបន់វាលទំនាប និងចុងក្រោយមាន ៥៣ភាគរយ នៃគ្រួសារកសិកម្ម នៅតំបន់បឹងទន្លេសាប បានធ្វើកសិកម្មក្នុងគោលបំណងចម្បងសម្រាប់ទុកប្រើប្រាស់ក្នុងគ្រួសារ។

**រូបទី៤ ៖ ភាគរយនៃគ្រួសារកសិកម្មបានធ្វើកសិកម្ម ដើម្បីគោលបំណងចម្បងសម្រាប់ទុកប្រើប្រាស់ក្នុងគ្រួសារ និងចម្បងសម្រាប់លក់**




ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២២

## ៣. ផលិតកម្មដំណាំ

ការអង្កេតនេះបានប៉ាន់ប្រមាណថា មានគ្រួសារកាន់កាប់កសិកម្មប្រមាណ ១ ៧៤៦ ០០០ គ្រួសារ ស្មើនឹង ៩៤ ភាគរយ បានធ្វើសកម្មភាពដាំដំណាំ ក្នុងចំណោមគ្រួសារកាន់កាប់កសិកម្មសរុបចំនួន ១ ៨៥៨ ៥៤០ គ្រួសារ។ ដំណាំជាច្រើនប្រភេទត្រូវបានរាយការណ៍ក្នុងអំឡុងពេលប្រមូលទិន្នន័យ ប៉ុន្តែការអង្កេតរបស់យើង គឺផ្តោតទៅលើដំណាំចំនួនតែ ៣០ មុខដំណាំប៉ុណ្ណោះ ដែលបានជ្រើសរើសថាជាដំណាំសំខាន់ ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីសួរព័ត៌មានលម្អិត ដូចជាផ្ទៃដីដាំដុះ ផ្ទៃដីប្រមូលផល ការប្រើប្រាស់ (ជី ថ្នាំសម្លាប់សត្វល្អិត ប្រព័ន្ធស្រោចស្រព) និងបរិមាណផលបានទទួល។

ការអង្កេតនេះបានចាត់ចំណាត់ថ្នាក់ដំណាំចម្បង ចំនួនបួនមុខដំណាំដែលគ្រួសារកសិកម្មបានដាំដុះច្រើនជាងគេ នៅក្នុងតំបន់ធំទាំងបួននៃប្រទេសកម្ពុជា។ ស្រូវធម្មតាត្រូវបានរកឃើញថាជាប្រភេទដំណាំដែលបានដាំច្រើនជាងគេបំផុត នៅទូទាំងប្រទេស ហើយបានប្រើប្រាស់ផ្ទៃដីដាំដុះដំណាំស្រូវធម្មតានេះ មានសរុប

ចំនួន ១,៨០ លាន ហិកតា និងផ្ទៃដីបានប្រមូលផលសរុបចំនួន ១,៧៨ លាន ហិកតា។ ទិន្នផលជាមធ្យមត្រូវបានរកឃើញថាមាន ចំនួន ២ ៩០០ គីឡូក្រាម/ហិកតា ខណៈដែលបរិមាណផលស្រូវធម្មតាសរុបទូទាំងប្រទេសមានចំនួនប្រមាណ ៥,១៨ លាន តោន ។ ការអង្កេតនេះក៏បានបង្ហាញផងដែរថា នៅប្រទេសកម្ពុជាបានដាំដុះដំណាំហូបផ្លែជាច្រើនប្រភេទរួមមាន៖ ស្វាយ ចេក ទៀប ស្រកានាគ ទុរេន ត្របែក ខ្នុរ ព្រីង មៀន ទឹកដោះគោ ល្ហុង និងម្នាស់។ នៅតំបន់វាលទំនាប និងតំបន់បឹងទន្លេសាប ដំណាំចេកជាដំណាំពេញនិយមជាងគេជាប់លំដាប់ទីពីរ។ ដូចគ្នាដែរនៅតំបន់វាលទំនាប និងតំបន់ភ្នំ និងខ្ពង់រាបវិញ ដំណាំចេកជាប់លំដាប់ទីពីរ ខណៈដែលដំណាំដូងជាប់លំដាប់ទីពីរផងដែរ នៅតំបន់ឆ្នេរសមុទ្រ។ នៅទូទាំងប្រទេស ផ្ទៃដីដាំដុះដំណាំចេកមានប្រមាណ ២២ ០០០ ហិកតា និងផ្ទៃដីប្រមូលផលបានប្រមាណ ១៤ ០០០ ហិកតា ជាមួយបរិមាណផលិតផលសរុប ៩០ ០០០ តោន។ ផ្ទៃដីដាំដុះដំណាំស្វាយមានប្រមាណ ៦០ ០០០ ហិកតា ដោយទទួលបរិមាណផលប្រហែល ៣៧៧ ០០០តោន។ ផ្ទៃដីដាំដុះដំណាំដូងមានប្រមាណ ១០ ០០០ ហិកតា និងផ្ទៃដីប្រមូលផលបានប្រមាណ ៩៩ ០០០ តោន និងផ្ទៃដីដាំស្វាយចន្ទីមានប្រមាណ ២៦៧ ០០០ ហិកតា ដោយទទួលបរិមាណផលប្រហែល ២១២ ០០០ តោន។

**រូបទី៥ ៖ ដំណាំចម្បងបួនប្រភេទ ដែលបានដាំច្រើនជាងគេនៅក្នុងតំបន់នីមួយៗ (ចំនួនគ្រួសារកសិកម្មដែលបានរាយការណ៍)**

**តំបន់វាលទំនាប៖**
**៥២០ ១៩០ គ្រួសារ**
១. ស្រូវធម្មតា
២. ចេក
៣. ស្វាយ
៤. ដូង

**តំបន់បឹងទន្លេសាប៖**
**៣៥៤ ០៥០ គ្រួសារ**
១. ស្រូវធម្មតា
២. ចេក
៣. ស្វាយ
៤. ដូង

**១ ១៣២ ៨៣០ គ្រួសារកាន់កាប់កសិកម្មបានធ្វើសកម្មភាពដាំដំណាំនៅទូទាំងប្រទេសកម្ពុជា**

**តំបន់ឆ្នេរសមុទ្រ៖**
**៩២ ៨០០ គ្រួសារ**
១. ស្រូវធម្មតា
២. ដូង
៣. ចេក
៤. ស្វាយ

**តំបន់ភ្នំ និងខ្ពង់រាប៖**
**១៦៥ ៧៩០ គ្រួសារ**
១. ស្រូវធម្មតា
២. ស្វាយ
៣. ចេក
៤. ស្វាយចន្ទី

ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២២

## ៤. សកម្មភាពចិញ្ចឹមបសុសត្វ និងបសុបក្សី

ការចិញ្ចឹមបសុសត្វ បសុបក្សីជាសកម្មភាពកសិកម្មដ៏សំខាន់នៅក្នុងប្រទេសកម្ពុជា វាជួយទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាជននិងផ្តល់ចំណូលដល់គ្រួសារកាន់កាប់កសិកម្មប្រមាណ ១ ៤២៤ ១១០ គ្រួសារ ស្មើនឹង ៧៦ ភាគរយ នៅក្នុងប្រទេស។ ក្នុងចំណោមគ្រួសារកាន់កាប់កសិកម្មសរុបនៅតំបន់ឆ្នេរសមុទ្រ បានរាយការណ៍ថា មានភាគរយគ្រួសារចិញ្ចឹមបសុសត្វ និង/ឬបសុបក្សីច្រើនជាងគេប្រមាណជា ៨៧ ភាគរយ និងមានភាគរយទាបជាងគេគឺនៅតំបន់វាលទំនាបមានប្រមាណ ៧៥ ភាគរយ បានចិញ្ចឹមបសុសត្វ និង/ឬបសុបក្សី ក្នុងចំណោមគ្រួសារកាន់កាប់កសិកម្មសរុបនៅតំបន់នេះ។ តាមការប៉ាន់ប្រមាណនៅទូទាំងប្រទេសមាន គ្រួសារចិញ្ចឹមសុបក្សីចំនួន ១ ១៥២ ៨៣០ គ្រួសារ និងគ្រួសារចិញ្ចឹមសត្វគោចំនួន ៧០៧ ៥៥០ គ្រួសារ។

**រូបទី៦ ៖ ចំនួនគ្រួសារកាន់កាប់កសិកម្ម ដែលបានរាយការណ៍ថាមានសកម្មភាពចិញ្ចឹមបសុសត្វ បសុបក្សី បែងចែកតាមតំបន់ (គិតជាពាន់)**




ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២២

នៅតំបន់វាលទំនាប មានចំនួនគ្រួសារចិញ្ចឹមសត្វគោច្រើនជាងគេ គឺប្រមាណ ៣១៩ ១៣០ គ្រួសារ បន្ទាប់មកនៅតំបន់បឹងទន្លេសាប មានចំនួន ២៣២ ០១០ គ្រួសារ ហើយនៅតំបន់ភ្នំ និងខ្ពង់រាប មានចំនួន ១០០ ៥៣០ គ្រួសារ និងតំបន់ឆ្នេរសមុទ្រ មានចំនួន ៥៥ ៨៨០ គ្រួសារ តិចជាងគេ។



*ប្រភពរូបថត៖ វិទ្យាស្ថានជាតិស្ថិតិឆ្នាំ២០២២*

នៅតំបន់វាលទំនាប បានបង្ហាញថា មានចំនួនគ្រួសារចិញ្ចឹមបសុបក្សី ច្រើនជាងគេ គឺចំនួន ៤៤៥ ១៥០ គ្រួសារ បន្ទាប់មកគឺតំបន់បឹងទន្លេសាប មានគ្រួសារចំនួន ៤១៦ ៤៨០ គ្រួសារ ហើយនៅតំបន់ភ្នំ និងខ្ពង់រាបមានគ្រួសារចំនួន ១៨៤ ៩៣០ គ្រួសារ និងនៅតំបន់ឆ្នេរសមុទ្រមានចំនួនគ្រួសារចិញ្ចឹមបសុបក្សីតិចជាងគេ គឺមានចំនួន ១០៦ ២៤០ គ្រួសារ។

តួលេខថ្នាក់ជាតិបានបង្ហាញថា ចំនួនសត្វគោជាមធ្យមក្នុង១គ្រួសារ មានចំនួន ៤,៤ ក្បាល ចំណែកបសុបក្សីមានចំនួន ២៤ ក្បាល ក្នុងមួយគ្រួសារកាន់កាប់កសិកម្ម។

## ៥. ការធ្វើសកម្មភាពវារីវប្បកម្ម និងនេសាទ

ការធ្វើវារីវប្បកម្ម ជាសកម្មភាពបំពេញចំណូលបន្ថែមក្នុងគ្រួសារកសិកម្មនៅប្រទេសកម្ពុជា តាមការប៉ាន់ប្រមាណមាន ៤ ភាគរយ នៃគ្រួសារកសិកម្មបានចូលរួមធ្វើសកម្មភាពវារីវប្បកម្ម ស្មើនឹងចំនួន ៧៦ ៩១០ គ្រួសារ។ ខណៈការនេសាទមានប្រមាណ ២៤ ភាគរយ ស្មើនឹងចំនួន ៤៥៤ ៦៣០ គ្រួសារ។ ហើយមានគ្រួសារកសិកម្មបានចូលរួមធ្វើសកម្មភាពទាំងពីរ ធ្វើវារីវប្បកម្ម និងនេសាទគឺ មានចំនួន ២៥ ៤៨០ គ្រួសារ ស្មើនឹង ១,៤ ភាគរយ នៃគ្រួសារកសិកម្មសរុប។ តំបន់ដែលមានចំនួនគ្រួសារច្រើនបំផុតធ្វើវារីវប្បកម្មគឺ នៅតំបន់វាលទំនាបមានចំនួន ៥៨ ៦១០ គ្រួសារ ស្មើនឹង ៨ ភាគរយ នៃគ្រួសារកសិកម្មសរុប។ ចំណែកឯនៅតំបន់បឹងទន្លេសាបវិញគឺ មានគ្រួសារកសិកម្មធ្វើសកម្មភាពនេសាទច្រើនជាងគេបំផុត គឺចំនួន ២០៩ ៧០០ គ្រួសារ ស្មើនឹង ៣០ ភាគរយ នៃគ្រួសារកាន់កាប់កសិកម្មសរុប។

**រូបទី៧ ៖ ចំនួនគ្រួសារកសិកម្មបានរាយការណ៍ថាមានសកម្មភាព វារីវប្បកម្ម និងឬនេសាទ ចែកតាមតំបន់**




ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២២

ក្នុងចំណោមគ្រួសារកសិកម្ម បានធ្វើសកម្មភាពនេសាទទាំងនោះ គឺមាន ៧៩ ភាគរយ បានរាយការណ៍ថានេសាទត្រី ហើយ ១៣ភាគរយ បានរាយការណ៍ថានេសាទ/ចាប់ក្តាម និង ៤ ភាគរយ រាយការណ៍ពីការនេសាទ/រកខ្ចង។ សម្រាប់បរិមាណផលសរុបដែលប្រមូលបានពីការនេសាទត្រីបានប្រមាណ ៣៧៥ លាន គីឡូក្រាម។

## ៦. បរិស្ថាន

ម៉ូឌុលនៃអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២២ គឺផ្តោត លើ "វិធីសាស្រ្តផលិតកម្ម និងបរិស្ថាន"។ នៅក្នុងម៉ូឌុលនេះទិន្នន័យស្ថិតិបរិស្ថានមួយចំនួនត្រូវបានរកឃើញថា មានផលប៉ះពាល់ដល់បរិស្ថានដល់ការប្រែប្រួលអាកាសធាតុ ការរិចរិលដី សម្ភារគ្រោះថ្នាក់ និងកាកសំណល់កសិកម្ម។

កញ្ចប់ថ្នាំកសិកម្ម និងប្លាស្ទិកដែលបានប្រើប្រាស់រួច គឺជាកាកសំណល់កសិកម្ម ដែលត្រូវបានកំណត់អត្តសញ្ញាណញឹកញាប់បំផុត មានចំនួន ២៤ ភាគរយ និង ១៩ ភាគរយ នៃគ្រួសារកសិកម្មសរុប។ កាកសំណល់ដែលបានបង្កើតដោយគ្រួសារកសិកម្មប្រើប្រាស់ត្រូវបានដុតចោលញឹកញាប់បំផុត(របាយការណ៍បង្ហាញថា ៣១ ភាគរយ កប់ក្នុងដី ១៤ ភាគរយ និងបោះចោលពាសវាលពាសកាលក្នុងកសិដ្ឋាន គ្មានការពារមានចំនួន ១២ ភាគរយ។

គ្រួសារកាន់កាប់កសិកម្ម ៥០ ភាគរយ ប្រើប្រាស់ប្រេងឥន្ធនៈនៃជាប្រភពថាមពលសម្រាប់ពួកគាត់ធ្វើកសិកម្ម បន្ទាប់មកបណ្តាញអគ្គិសនីមានចំនួន ២៦ ភាគរយ និងថាមពលពន្លឺព្រះអាទិត្យមានត្រឹមតែ ២ ភាគរយ ប៉ុណ្ណោះ។ គ្រួសារកសិកម្មបានរាយការណ៍ថា ការចំណាយថ្លៃដើមជាមធ្យមក្នុងមួយខែលើថ្លៃប្រេងឥន្ធនៈ ការប្រើគ្រឿងយន្តកសិកម្ម សម្ភារកសិម្ម និងយានជំនិះ នៅរដូវប្រាំងតម្លៃជាមធ្យមចំនួន ១៧២ ០០០ រៀល ខ្ពស់ជាងនៅរដូវវស្សាមានតម្លៃជាមធ្យមចំនួន ១៥៤ ០០០ រៀល។

គ្រួសារកសិកម្មចំនួន ៣៩ ភាគរយ បានរាយការណ៍ថា មិនមានក្តីកង្វល់ពីបរិស្ថានណាមួយទេក្នុងអំឡុងពេលឆ្នាំយោង។ គ្រួសារកសិកម្មដែលបានរាយការណ៍ពីការព្រួយបារម្ភខ្លាំងជាគេនោះ គឺគ្រោះរាំងស្ងួតមានចំនួន ២៥ ភាគរយ សីតុណ្ហភាពកើនឡើងខ្លាំងចំនួន ១៩ ភាគរយ និងបញ្ហាទឹកជំនន់ចំនួន ១៨ ភាគរយ នៃគ្រួសារកសិកម្មសរុប។

គ្រួសារកសិកម្មចំនួន ១៩ ភាគរយ បានរាយការណ៍ថា បានកែប្រែវិធីសាស្រ្តដាំដុះពីឆ្នាំមុនភាគច្រើន គឺប្រើប្រាស់គ្រាប់ពូជតាមបែបប្រពៃណី (មានចំនួន ១១ ភាគរយ)។

គ្រួសារកាន់កាប់កសិកម្មចំនួន ១៧ ភាគរយ បានជួបប្រទះគ្រោះហានីភ័យធ្ងន់ធ្ងរក្នុងអំឡុងពេល១២ខែចុងក្រោយ។ ក្នុងចំណោមគ្រួសារកាន់កាប់កសិកម្មចំនួន ៩ ភាគរយ បានរាយការណ៍ថាបានរងផលប៉ះពាល់ធ្ងន់ធ្ងរដោយសារគ្រោះទឹកជំនន់។

ជីលាមកសត្វ គឺជាជីសរីរាង្គចម្បងដែលត្រូវបានប្រើប្រាស់ ដោយគ្រួសារកសិកម្ម មាន ២៨ ភាគរយ ក្នុងគ្រួសារ។ ជីសរីរាង្គដែលបានប្រើប្រាស់ច្រើនជាងគេលំដាប់ទី២នោះ គឺបន្លែរលួយ ឬជីកំប៉ុស ដែលមានចំនួន ២ ភាគរយ នៃគ្រួសារកសិកម្ម។

គ្រួសារកាន់កាប់កសិកម្ម នៅតែប្រើប្រាស់ជីគីមីមានចំនួនច្រើនជាងជីសរីរាង្គ មានចំនួន ៤០ ភាគរយ ជី NPK (៣៣ ភាគរយ) និងជី DAP (១៦ ភាគរយ)។ គ្រួសារកសិកម្ម ចំនួន ៩ ភាគរយ បានរាយការណ៍ថាមិនបានប្រើប្រាស់ជី មូលហេតុដោយសារតែតម្លៃជីមានការកើនឡើងថ្លៃពេក។ ក្នុងចំណោមគ្រួសារកសិកម្ម ដែលរាយការណ៍ថាបានប្រើប្រាស់ជីគីមី ៦៤ ភាគរយ បានដឹងពីហានិភ័យ បរិស្ថានដែលទាក់ទងនឹងការប្រើប្រាស់ជីហួសកម្រិត ឬការប្រើប្រាស់ខុសបច្ចេកទេស ដោយឡែក ៦១ ភាគរយ មិនមានវិធានការណាមួយជាក់លាក់ ដើម្បីកាត់បន្ថយហានិភ័យបរិស្ថាននេះទេ។

ថ្នាំសម្លាប់សត្វចង្រៃផ្សេងៗ ក៏ត្រូវបានប្រើប្រាស់ក្នុងចំនួនច្រើនផងដែរ។ ថ្នាំសម្លាប់ស្មៅ (រាវ) ប្រើចំនួន ៣១ ភាគរយ ថ្នាំសម្លាប់សត្វចង្រៃប្រើចំនួន ២២ ភាគរយ ថ្នាំសម្លាប់ស្មៅ (រឹង) ប្រើចំនួន ១០ ភាគរយ និងថ្នាំសម្លាប់ខ្យង ប្រើចំនួន ៦ ភាគរយ នៃគ្រួសារកសិកម្មសរុប។ ក្នុងចំណោមគ្រួសារកសិកម្មចំនួន ៧៥ ភាគរយ បានរាយការណ៍ថាបានដឹងពីហានិភ័យបរិស្ថាន និងសុខភាពដែលទាក់ទងនឹងការប្រើប្រាស់ថ្នាំសម្លាប់សត្វចង្រៃហួសកម្រិត ឬការប្រើប្រាស់ខុសបច្ចេកទេស ដោយឡែកមានតែគ្រួសារកសិកម្មចំនួន ៥៦ ភាគរយ ប៉ុណ្ណោះដែលបានរាយការណ៍ថាបានចាត់វិធានការជាក់លាក់ ដើម្បីកាត់បន្ថយហានិភ័យសុខភាព ខណៈដែល ៤៧ ភាគរយ បានរាយការណ៍ថាកំពុងចាត់វិធានការជាក់លាក់ ដើម្បីកាត់បន្ថយហានិភ័យបរិស្ថាន។



*ប្រភពរូបថត៖ វិទ្យាស្ថានជាតិស្ថិតិឆ្នាំ២០២២*

## ៧. ទំនាក់ទំនង

វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានសហការគ្នាធ្វើអង្កេត និងចេញរបាយការណ៍ចុងក្រោយ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២២ នៅខែធ្នូ ឆ្នាំ២០២៤។ របាយការណ៍អាចស្វែងរកបាននៅគេហទំព័រវិទ្យាស្ថានជាតិស្ថិតិ។

| អង្កេតកសិកម្មកម្ពុជា | |
|---|---|
| អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ (FAO) https://www.fao.org/cambodia/en/ | តំណាងអង្គការ FAO នៅកម្ពុជា មានអាស័យដ្ឋាននៅក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ផ្ទះលេខ២០០ មហាវិថីព្រះនរោត្តម សង្កាត់ ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា |
| វិទ្យាស្ថានជាតិស្ថិតិ (NIS) នៃក្រសួងផែនការ (MoP) https://www.nis.gov.kh/ | វិទ្យាស្ថានជាតិស្ថិតិ (NIS) ក្រសួងផែនការ (MoP) រាជរដ្ឋាភិបាលកម្ពុជា អគារ C, E និង F #៣៦៨ ព្រះមុនីវង្ស Blvd សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា |
| ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) https://web.maff.gov.kh/ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) ២៥៥, ២០០ វិថីព្រះនរត្តម រាជធានីភ្នំពេញ Blvd (៤១) |

គាំទ្របច្ចេកទេសដោយ៖

Food and Agriculture Organization of the United Nations

គាំទ្រហិរញ្ញវត្ថុដោយ៖

50x2030 DATA-SMART AGRICULTURE